**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**:..១៨១...អនក្រ.បក

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ:...៩៧...
មកដល់ថ្ងៃទី[illegible] ខែ០១ ឆ្នាំ១៩
ម៉ោង...០៣:៣១...

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមាត្រា ៤ និង មាត្រា ៧ នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រាមួយ** .-

ត្រូវបានកែសម្រួលមាត្រា ៤ និងមាត្រា ៧ នៃអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានខ្លឹមសារដូចខាងក្រោម៖

**មាត្រា៤ ថ្មី ..**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ "គ.ក.រ" ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងវិស័យកែទម្រង់រដ្ឋបាលសាធារណៈ ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រសួងមុខងារសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈឬតំណាង (រដ្ឋលេខាធិការ) | | ប្រធាន |
| ២-តំណាងក្រសួងមុខងារសាធារណៈ(រដ្ឋលេខាធិការ និង ឬ អនុរដ្ឋលេខាធិការ) | | អនុប្រធាន |
| ៣- តំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | មួយរូប | អនុប្រធាន |
| ៤- តំណាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | មួយរូប | អនុប្រធាន |
| ៥- តំណាងនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ចំណុះរាជរដ្ឋាភិបាល (រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការ) | មួយរូប | សមាជិក |
| ៦-តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | មួយរូប | សមាជិក |
| ៧-តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី | មួយរូប | សមាជិក |
| ៨-តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី | មួយរូប | សមាជិក |
| ៩-អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | | សមាជិក |
| ១០-អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ | | សមាជិក |
| ១១-អគ្គាធិការនៃក្រសួងមុខងារសាធារណៈ | | សមាជិក |
| ១២-តំណាងសាលាភូមិន្ទរដ្ឋបាល | | សមាជិក |
| ១៣- តំណាងគណៈអភិបាលរាជធានី ខេត្ត (អភិបាល ឬ អភិបាលរង) | មួយរូប | សមាជិក |

ក្រៅពីសមាជិកខាងលើ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អាចស្នើបន្ថែមសមាជិកដែលជាតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ឬ មន្ត្រីជំនាញជាន់ខ្ពស់ផ្សេងទៀត តាមការចាំបាច់។

ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ ការតែងតាំងសមាសភាពផ្សេងទៀតនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ ថ្មី ..**

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈត្រូវធ្វើការប្រជុំត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ រៀងរាល់០៣ (បី) ខែម្តង និងអាចប្រជុំផ្សេងទៀតតាមការចាំបាច់។

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈធ្វើការតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន អនុប្រធាន និង សមាជិកគណៈកម្មាធិការត្រូវចាត់តាំងតំណាងចូលរួម ដែលមានសិទ្ធិសម្រេចជំនួសខ្លួន។

**មាត្រាពីរ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី** ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ